# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៥៤ សសរ...**

## សេចក្តីសម្រេច
## ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវហេតុការណ៍ដែលនាំឲ្យកើតមានអំពើហឹង្សា នៅបង្គោលព្រំដែនលេខ២០៣ តំបន់ព្រំដែនកម្ពុជា-វៀតណាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវស៊ើបបញ្ជាក់ហេតុការណ៍ ដែលនាំឲ្យកើតមានអំពើហឹង្សា នៅបង្គោលព្រំដែនលេខ២០៣ (ទួលតាព្រាប) តំបន់ព្រំដែន កម្ពុជា-វៀតណាម ស្ថិតនៅភូមិថ្លុកថ្មី ឃុំត្នោត ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដែលមាន សមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន
២-ឯកឧត្តម នាយឧត្តមសេនីយ៍ **ឌុល គឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣-ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯល ម៉ាន់សាវ៉ាត** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន
៤-ឯកឧត្តម នាយឧត្តមសេនីយ៍ **សំរិទ្ធ ឌី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៥-ឯកឧត្តម **ជៀង អំ** អភិបាលខេត្តស្វាយរៀង សមាជិក
៦-ឯកឧត្តម នាយឧត្តមសេនីយ៍ **ដាំ ឧទ្ធី** អគ្គស្នងការរងនគរបាលជាតិ សមាជិក
៧-ឯកឧត្តម **គីម ចន្ទ្យសោភ័ណ** អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក
៨-ឯកឧត្តម **ស៊ិន សូធានី** អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍អាជ្ញាធរជាតិកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៩-ឧត្តមសេនីយ៍ត្រី **ភឹង ឃន** ស្នងការនគរបាលខេត្តស្វាយរៀង សមាជិក

**ប្រការ២.-**

គណៈកម្មការមានភារកិច្ចដូចខាងក្រោម៖

-ទំនាក់ទំនង ជាមួយភាគីវៀតណាម ដើម្បីស្រាវជ្រាវស៊ើបបញ្ជាក់ហេតុការណ៍ ដែលកើតមាននៅចំណុចបង្គោលព្រំដែន លេខ២០៣ស្ថិតនៅភូមិធ្លកថ្មី ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

-ប្រមូលផ្តុំគ្រប់ឯកសារដែលពាក់ព័ន្ធទាំងផ្នែកច្បាប់ និងផ្នែកបច្ចេកទេសកិច្ចការខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម ដើម្បីជាមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់ ពិភាក្សា និងដោះស្រាយ ។

-ចុះអង្កេតស្រាវជ្រាវជាក់ស្តែងដល់ទីកន្លែងកើតហេតុ ដើម្បីប្រមូលព័ត៌មាន វត្ថុតាង សាក្សី សម្រាប់កសាងឯកសារ ធ្វើការដោះស្រាយ ។

-ធ្វើសេចក្តីរាយការណ៍សុំយោបល់ដឹកនាំ និងការសម្រេចពីប្រមុខរាជរដ្ឋាភិបាល តាមរយៈសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមដំណាក់កាលការងារនិមួយៗ ។

-ធ្វើរបាយការណ៍បូកសរុបលទ្ធផល និងផ្តើមឡើងនូវវិធានការជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច ។

**ប្រការ៣.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបំពេញការងារ និងមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តស្វាយរៀង គ្រប់ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រីស្តីទី**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ